# ជំនឿ និងទំនៀមទេសន៍មហាជាតក៍ក្នុងសង្គមខ្មែរ

បើនិយាយសាមញ្ញខ្ញីងាយយល់ "មហាជាតក៍" គឺជារឿងវេស្សន្តរ ឬដែលចាស់ជាន់ដើមច្រើននិយមហៅថា "មហាវេស្សន្តរ"។ បើនិយាយមួយបែបផ្សេង "មហាជាតក៍" គឺជាជាតិធំបង្អស់[១] ជាតិចុងបំផុតរបស់ព្រះវេស្សន្តរ ជាព្រះពោធិសត្វដែលបានបំពេញបារមីដ៏មហស្ចារ្យ ពោលគឺទានបារមី ដើម្បីបានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងជាតិមុខ។ ជាតកមួយនេះ មានផ្ទៃរឿងវែងអន្ធាយរហូតដល់១៣កណ្ឌ រៀបរាប់ដំណើរជីវិត និងការបំពេញទានរបស់ព្រះវេស្សន្តរ រាប់តាំងពីដំរីបច្ច័យនាគ បរិច្ចាគសត្តសតកមហាទាន ប្រទានសេះរាជរថ រហូតទីបំផុតបានដាក់ទានជាលី និងក្រស្នាជាបុត្រ ព្រមទាំងប្រកាសនឹងបរិច្ចាគនាងមទ្រី និងខ្លួនព្រះអង្គថ្វាយជាទានផង។ ចិត្តសទ្ធាបំពេញទានដ៏ជ្រះថ្លារបស់ព្រះអង្គមានតាំងពីគង់នៅនគរស្រីពិរាស្ត្ររហូតក្នុងដំណើរតាមផ្លូវទៅគង់នៅក្នុងព្រៃភ្នំគិរីវង្គត។ បើធៀបនឹងជាតកផ្សេងទៀតក្នុងបណ្ដាទសជាតក ឬជាតកទាំង១០ មហាវេស្សន្តរជាតកហាក់ដូចជាពេញនិយមក្រៃលែងក្នុងសង្គមពុទ្ធសាសនាតាំងពីដើមរៀងមក។ គេឃើញសាច់រឿងនេះ មានកត់ត្រាចារទុកក្នុងសាស្ត្រាស្លឹករឹតរក្សាតាមវត្តនានាជាច្រើន ប្រកបដោយខ្លឹមសារវែងខ្លី និងពាក្យពេចន៍ពីរោះបែបកម្រងកែវផង។ ការកត់ត្រាចារចម្លង ក៏សម្បូរបែបតម្រូវតាមទំនៀម និងតម្រូវការជាក់ស្ដែងនៃវត្តនីមួយៗ ដែលហ្នឹងនិពន្ធមន្ត្រីញ៉ុក ថែម ធ្លាប់លើកយកមករួបរួមពិនិត្យតាំងពីឆ្នាំ១៩៦៦ ហើយព្រះភិក្ខុវិនយធរោមហាយិន នឿន បានយកស្នាដៃនោះមកបោះពុម្ពឡើងវិញនៅឆ្នាំ១៩៩០។

ក្នុងបរិបទសង្គមខ្មែរការនិយមរឿងមហាវេស្សន្តរ គេសង្កេតឃើញលើកឡើងតាំងពីក្នុងសិលាចារឹក[២] ឆ្លាក់តាមប្រាសាទ[៣] សម្ដែងជាល្ខោន គំនូរតាមវិហារ[៤] ចម្លាក់លម្អតាមវត្ត រហូតលើកទេសន៍ក្លាយជាទំនៀម"ទេសន៍មហាជាតក៍"[៥] យ៉ាងឱឡារឹកអធឹកអធមតាម

[១] អ៊ូ គង្គា និង ទៀវ វិចិត្រ ២០១៧: ៣២-៣៧

[២] កូវ គំនិត ២០១០: ៤-១២

[៣] ទៀវ វិចិត្រ ២០១០

[៤] សាន ផល្លា ២០០៧

[៥] ទេសន៍មហាជាតក៍ ពុំមានបញ្ញត្តិក្នុងព្រះវិន័យដូច កឋិន ចូល-ចេញព្រះវស្សា វិសាខបូជា ឬមាឃបូជាទេ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

វត្តអារាមនានា។ ការលើកមកទេសន៍នេះ ដើមឡើយមានស្ទើរតែគ្រប់វត្តក្នុងស្រុកខ្មែរ ហើយច្រើននិយមធ្វើក្រោយចេញវស្សា។[៦] ប៉ុន្តែទំនៀមនេះ ចេះតែរៀវរោយថយចុះជាលំដាប់ វត្តខ្លះក៏ខានធ្វើសោះ វត្តខ្លះក៏ធ្វើគ្រាន់តែជាគម្រប់ការប៉ុណ្ណោះ។ ចំពោះវត្តខ្លះ នៅប្រារព្ធមកដល់សព្វថ្ងៃ ភាគច្រើននៅតំបន់សៀមរាប មួយភាគតូចនៅជាយក្រុងភ្នំពេញ និងវត្តមួយនៅតំបន់ភ្នំវល្លិ៍ ខេត្តកំពត។ ប៉ុន្តែការលើកមកទេសន៍នៅវត្តនីមួយៗខាងលើក៏ធ្វើក្នុងពេល និងបុព្វហេតុផ្សេងគ្នាដែរ។ វត្តយាង វត្តចេតិយ និងវត្តប្រដាក នៅខេត្តសៀមរាប លើកមកទេសន៍តាមបែបប្រពៃណីពីបុរាណ។ ចំណែកវត្តអង្គរខាងត្បូង នៃខេត្តសៀមរាប និងវត្តគល់ទទឹងស្ថិតនៅមិនឆ្ងាយពីក្រុងភ្នំពេញ ហាក់ដូចជាខំគាស់កកាយធ្វើតាមទំនៀមចាស់ ដើម្បីក្មេងជាន់ក្រោយបានស្គាល់ផង និងដើម្បីភ្នែកទេសចរណ៍ឃើញផង។ ទិដ្ឋភាពនេះហាក់មិនប្លែកអ្វីឡើយ ដ្បិតចុងបំផុតនៃរឿងមហាវេស្សន្តរសម្តែងចែងច្បាស់ថា "វេស្សន្តរជាតក៍ ហៃសាធុជនសប្បុរសផងទាំងឡាយអើយថា បើបុរសបុគ្គលឯណា បានស្តាប់ត្រាប់ត្រងរងរសអាថ៌ធម៌វិសេសទេសនាមហាវេស្សន្តរជាតកនេះហើយ ក៏សឹងរំដោះប្រាសចាកទុក្ខសោករោគភ័យចង្រៃឧបទ្រពផងទាំងឡាយ ទៅនៅក្នុងលោកិយក៏ប្រសើរ លុះអនាគតកាលទៅឯភ្នែកក៏សឹងលុះសោតា សកិទា អនាគា អរហត្តផល បានដល់សម្បត្តិព្រះនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្ត ប្រសើរនោះទៀងប្រាកដហោង"។[៧]

ដោយឡែកចំពោះវត្តពីរល្វែង ដែលស្ថិតនៅជាប់ទួលអ្នកតាមួយក្បែរជើងភ្នំ នៃតំបន់ភ្នំវល្លិ៍ ក្នុងខេត្តកំពត មានទំនៀមទេសន៍មហាជាតក៍៣ យប់៣ ថ្ងៃ មុននឹងបញ្ចប់ត្រង់កិច្ចឡើងអ្នកតានៅថ្ងៃចុងក្រោយ។[៨] ទំនៀមអ្នកស្រុករស់នៅតំបន់ នេះហាក់មានឫសគល់គួរពិចារណាក្នុងជំនឿខ្មែរ អំពីរឿងភ្លៀងផ្គរសម្រាប់របរកសិកម្ម ដ្បិតកង្វល់ធំបំផុត គឺដើម្បីសុំទឹកភ្លៀងសម្រាប់ធ្វើស្រែចម្ការ។ កង្វល់នេះ ពុំខុសគ្នាឡើយពីកង្វល់របស់អ្នក

---

[៦] ពេជ្រ សល់ និង ញូង សឿន ១៩៦៦:៦០-៦១

[៧] យិន នឿន ១៩៩០: ៤៨៨

[៨] សូមអានបន្ថែម៖ យាយម៉ៅ និងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍ https://www.yosothor.org/publications/khmer-renaissance/chapter-two/Yeymoa.html

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ស្រុកកលិង្គរាស្រ្ត ត្រង់កណ្ឌទី២ (ហេមពាន្ត) ក្នុងមហាវេស្សន្តរជាតក ដែលជួបគ្រោះទុរភិក្ស ទៅប្រាថ្នាសុំដំរីមង្គលបច្ច័យនាគពីព្រះវេស្សន្តរ ដើម្បីឱ្យស្រុកភូមិមានភ្លៀងធ្លាក់ អ្នកស្រុករស់នៅបានសុខសប្បាយឡើងវិញ។ ក្រោយបានដំរីមង្គលនោះហើយ ភ្លៀងបោក្ខរព័ស៌[៩] ក៏បង្អុរចុះមកដូចបំណង។ ទិដ្ឋភាពត្រង់ចំណុចនេះខ្មែរទូទៅមិនពិបាកយល់ទេអំពីជំនឿលើដំរីពាក់ព័ន្ធនឹងភ្លៀង ព្រោះសូមកុំភ្លេចថា បើនរណាម្នាក់យល់សប្តិឃើញដំរី គេជឿថានឹងមានភ្លៀងធ្លាក់ឆាប់ៗ ហើយបើពេលណាមួយឃើញសរសៃសៗ (ខ្លះហៅអំបោះខ្មោច) រសាត់ព្រោងព្រាតតាមខ្យល់ ក៏គេជឿថាភ្លៀងនឹងធ្លាក់មកឆាប់ៗ ដ្បិតគេយល់ថា សរសៃឆ្មារៗពណ៌សៗនេះជាសរសៃចេញពីដើមឈូកដែលដំរីកាច់ស៊ីមុនពេលភ្លៀងធ្លាក់។ ចំពោះជំនឿលើដំរីនិងទឹកភ្លៀងនេះ បើមើលហួសដល់ទំនៀមអ្នកស្រុកជុំវិញប្រាសាទបាកាន្ត(ខេត្តព្រះវិហារ) គេឃើញកាន់តែច្បាស់នៅត្រង់ពិធីស្រង់អ្នកតាព្រះដំរី នៅប្រាសាទព្រះដំរីរៀងរាល់ថ្ងៃចូលឆ្នាំចុងក្រោយ។ ម្នាក់ៗយកទឹកអប់ភ្ញីផ្កា ទៅស្រោចស្រពលើចម្លាក់ដំរីបុរាណមួយគូ សល់នៅតាមជ្រុងប្រាសាទនោះ ក្នុងជំនឿ ដើម្បីសុំភ្លៀង។ រីឯត្រង់កណ្ឌឆក្សត្រ ដែលស្តេចទាំង៦ អង្គ គឺព្រះបាទស្រីសញ្ជ័យ ព្រះនាងសុបារសុប្បីតី ព្រះវេស្សន្តរ ព្រះនាងមទ្រី ជាលី និង ក្រស្នា បានជួបគ្នាវិញ ភ្លៀងបោក្ខរព័ស៌ ក៏ធ្លាក់មកស្រោចស្រពផែនដីម្តងទៀត។ បើនិយាយក្នុងបរិបទទេសន៍មហាជាតក៍សុំទឹកភ្លៀង ប្រការទាំងនេះហើយ គឺជាហេតុផលពន្យល់បានមួយចំណែកក្នុងជំនឿខ្មែរ៕

---

[៩] ភ្លៀងនេះដូចទឹកលើស្លឹកឈូក ប្លែកពីភ្លៀងធម្មតា បើនរណាចង់ទទឹកក៏ទទឹក បើមិនប្រាថ្នាចង់ទទឹកទេ ភ្លៀងក៏មិនទទឹកខ្លួនដែរ។ តាមក្នុងពុទ្ធប្រវត្តិ ភ្លៀងនេះធ្លាក់តែក្នុងជាតិវេស្សន្តរ និងនៅពេលដែលព្រះពុទ្ធអង្គនិមន្តប្រោសពួកញាតិនាក្រុងកបិលពស្តុ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព



រូបលេខ១៖ គំនូរបុរាណត្រង់ឈុតព្រះវេស្សន្តរប្រទានដំរីបច្ច័យនាគដល់អ្នកស្រុកកលិង្គរាស្ត្រ (គំនូរហប់ខ្យល់ នៅវត្តចិនដំដែក)



រូបលេខ២៖ ព្រះវេស្សន្តរប្រទានសេះ និងរាជរថ (គំនូរវត្តតាំងតុ, អង្គរជំ)



រូបលេខ៣៖ ព្រះវេស្សន្តរដាក់ទានជាលី និងក្រស្នាទៅជជូកព្រាហ្មណ៍ (គំនូរវត្តចិនដំដែក)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ២៤៖ ពុទ្ធបរិស័ទរៀបគ្រឿងសក្ការៈ មុនព្រះសង្ឃសម្តែងធម្មទេសនាមហាជាតក៍ (វត្តប្រដាក)



រូបលេខ២៥៖ កូនអ្នកស្រុកតែងខ្លួនជាតួអង្គក្នុងរឿងព្រះវេស្សន្តរក្នុងកិច្ចទេសន៍មហាជាតក៍ (វត្តប្រដាក)



រូបលេខ២៦៖ ព្រះសង្ឃគង់ទេសនាមហាជាតក៍(វត្តប្រដាក)



រូបលេខ២៧៖ កិច្ចហែប្រទក្សិណាត្រង់ចក្សុត្រជួបគ្នា(វត្តប្រដាក)



រូបលេខ២៦៖ រណ្តាប់ និងបន្លែផ្លែឈើរៀបចំក្នុងកិច្ចទេសន៍មហាជាតក៍(វត្តចេតិយ)



រូបលេខ២៧៖ ព្រះសង្ឃគង់ទេសន៍មហាជាតក៍វេលាថ្ងៃ(វត្តពីរល្វែង)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## ឯកសារយោង

កូវ គំនិត

២០១០, *ទេសន៍មហាជាតក៍*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, ភ្នំពេញ

ញ៉ុក ថៃម

១៩៦៦, *មហាវេស្សន្តរជាតក*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ពេជ្រ សល់ និង ញូង សឿន

១៩៦៦, *ពិធីបុណ្យប្រចាំខែទាំងដប់ពីរ*, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

យិន នឿន

១៩៩០, *មហាវេស្សន្តរជាតក*, វត្តខេមរពុទ្ធិការាម, ឡុងប៊ិក

សាន ផល្លា

២០០៧, *គំនូរតាមវត្ត*, រៃយំ, ភ្នំពេញ

ហ៊ួន សារ៉ង

*សូមទឹកភ្លៀងនៅភ្នំវល្លិ៍*

https://www.yosothor.org/publications/khmer-renaissance/chapter-seven/som-terk-pleang-nov-vor-phnom.html

*យាយម៉ៅ និងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍*

https://www.yosothor.org/publications/khmer-renaissance/chapter-two/Yeymoa.html

អ៊ូ គង្គា និង ទៀវ វិចិត្រ

២០២០ "ពិធីបុណ្យទេសន៍មហាជាតក" *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, យសោធរ, ភ្នំពេញ, ទំ. ៣២-៣៧


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត